ក្រុមសៀវភៅការរុករកឃើញ®

# តើសេចក្តីស្លាប់

## គឺជាទីបញ្ចប់មែនឬ?

Death : Is it the end?



នាំមកជូនដោយ នំម៉ាណាប្រចាំថ្ងៃ

ការស្វែងយល់
ស៊ីជម្រៅ




## តើសេចក្ដីស្លាប់ គឺជាទីបញ្ចប់មែនឬ?

មិត្តភក្តិរបស់ខ្ញុំម្នាក់ គឺជាទាហានឆ័ត្រយោង ហើយបានចូលប្រយុទ្ធនៅក្នុងសង្គ្រាមជាច្រើន។ គាត់មិនមែនជាគ្រីស្ទបរិស័ទទេ តែពេលណាគាត់និយាយអំពីបទពិសោធន៍ក្នុងសង្គ្រាមម្ដងៗ គាត់តែងតែនិយាយថា "នៅសមភូមិ ខ្ញុំមិនដែលឃើញអ្នកដែលមិនជឿថាមានព្រះនោះទេ"។ ពេលដែលគាត់និយាយអំពីរឿងនេះជាលើកទីមួយ ខ្ញុំគិតថាគាត់គ្រាន់តែនិយាយលេងទេ ប៉ុន្តែ ខ្ញុំឃើញទឹកមុខគាត់ញញឹម។

គាត់ថា ពេលដែលគ្រាប់កាំភ្លើងជាច្រើនគ្រាប់បានហោះជិតត្រូវក្បាលគាត់ គាត់ក៏បានដឹងថា សេចក្ដីស្លាប់អាចឆក់យកជីវិតគាត់នៅពេលណាក៏បាន ហេតុនេះហើយ គាត់ស្រែកអំពាវរកព្រះ ដោយការភ័យខ្លាច។ គឺនៅពេលដែលគាត់គិតថា គាត់ជិតដល់ពេលស្លាប់ គាត់ក៏បានទូលសូមឲ្យព្រះជាម្ចាស់ជួយគាត់។ មនុស្សភាគច្រើនអាចយល់ អំពីការភ័យខ្លាច ចំពោះសេចក្ដីស្លាប់ ដូចដែលមិត្តភក្តិខ្ញុំបានពិសោធដោយផ្ទាល់ ទោះបីជាយើងមិនដែលធ្លាប់ចូលសមរភូមិប្រយុទ្ធក៏ដោយ។

---

*"នៅសមរភូមិ ខ្ញុំមិនដែលឃើញអ្នកដែលមិនជឿថាមានព្រះនោះទេ"។*

---

តែគ្រាន់តែការប្រយុទ្ធគ្នាបានបញ្ចប់ភ្លាម ហើយការបាញ់ប្រហាររបស់សត្រូវក៏បានឈប់ គាត់ក៏បានភ្លេចព្រះ ... គឺយ៉ាងហោចណាស់ ទាល់តែដល់ពេលដែលគាត់ស្ថិតក្នុងទីលានប្រយុទ្ធម្តងទៀត ទើបគាត់នឹកចាំអំពីទ្រង់ឡើងវិញ។ —Russell Fralick

----------------

*"យើងនឹងប្រឈមមុខនឹងសេចក្តីស្លាប់នៅពេលណាមួយជាមិនខាន ព្រោះសេចក្តីស្លាប់ពិតជាទៀងណាស់"។*

----------------

ជាការពិតណាស់ មនុស្សភាគច្រើនមិនដែលបានចូលប្រយុទ្ធក្នុងសមរភូមិទេ ហេតុនេះហើយ ជារៀងរាល់ថ្ងៃ យើងកម្រនឹងគិតថា សេចក្តីស្លាប់អាចនឹងឆក់យកជីវិតយើងនៅពេលណាក៏បាន។ ទោះជាយ៉ាងណាក៏ដោយ យើងនឹងប្រឈមមុខនឹងសេចក្តីស្លាប់នៅពេលណាមួយជាមិនខាន ព្រោះសេចក្តីស្លាប់ពិតជាទៀងណាស់។ ប៉ុន្តែ បន្ទាប់ពីយើងស្លាប់ហើយ តើនឹងមានអ្វីកើតឡើងចំពោះយើង ជាបន្ទាប់ទៀត? ហើយតើយើងបានត្រៀមខ្លួនសម្រាប់សេចក្តីស្លាប់ហើយឬនៅ? យើងចាំបាច់ត្រូវគិតអំពីសេចក្តីស្លាប់ ឲ្យបានជិតដល់ ហើយត្រូវប្រាកដថា យើងបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការអ្វីដែលយើងនឹងជួប បន្ទាប់ពីយើងស្លាប់ទៅ។



## តាមជំនឿរបស់គ្រីស្ទបរិស័ទ

**គ្រីស្ទបរិស័ទជឿថា** ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ កាលជាង២ពាន់ឆ្នាំមុន បន្ទាប់ពីទ្រង់សុគតបានបីថ្ងៃ។ សម្រាប់គ្រីស្ទបរិស័ទ ផ្នូររបស់ព្រះយេស៊ូវដែលនៅទទេ គឺជាគន្លឹះដែលនាំឲ្យពួកគេមានជំនឿថា ពួកគេក៏នឹងមានជីវិតរស់នៅជារៀងរហូតជាមួយទ្រង់ បន្ទាប់ពីពួកគេស្លាប់ទៅ។ និយាយឲ្យខ្លី នេះជាភស្តុតាងបញ្ជាក់ថា សេចក្ដីស្លាប់មិនមែនជាចុងបញ្ចប់ឡើយ។

មនុស្សជាច្រើនមិនដឹងថា នឹងមានអ្វីកើតឡើង បន្ទាប់ពីខ្លួនស្លាប់ឡើយ។ ហើយក្រៅពីគ្រីស្ទបរិស័ទ កម្រនឹងមាននរណាម្នាក់ជឿថា ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ គឺជាការពិតដែលបានកើតឡើងជាប្រវត្តិសាស្ត្រ។ មនុស្សជាច្រើនគិតថា ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ គ្រាន់តែជារឿងនិទានបែបប្រឌិតប៉ុណ្ណោះ។

*"មនុស្សជាច្រើនមិន* ***ដឹងថា*** *នឹងមានអ្វីកើតឡើង* ***បន្ទាប់ពីខ្លួនស្លាប់ឡើយ*** *"។*

គេយល់ថា ការដែលមនុស្សម្នាក់មានជីវិតរស់ឡើងវិញ បន្ទាប់ពីគេបានយកសពទៅកប់ពីរបីថ្ងៃហើយ គឺជារឿងឡប់ៗមិនគួរឲ្យជឿ។

តែកាលពីជាង២ពាន់ឆ្នាំមុន ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង។ នៅថ្ងៃដដែលនោះ មុនពេលថ្ងៃលិច មិត្តសំឡាញ់ទ្រង់ក៏បានយកព្រះសពទ្រង់ ទៅបញ្ចុះក្នុងផ្នូរ។ ហើយសត្រូវរបស់ទ្រង់ថែមទាំងបានសន្ទប់មាត់ផ្នូរទ្រង់ ហើយបានឲ្យពួកទាហានយាមផ្នូរទ្រង់ទៀត ដើម្បីកុំឲ្យមាននរណាម្នាក់មកលួចសពទ្រង់ ហើយប្រកាស់ថា ទ្រង់បានមានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែ ព្រះគម្ពីរបានចែងឲ្យយើងដឹងថា បីថ្ងៃក្រោយមក ទ្រង់បានយាង

ចេញពីផ្នូរ។ ពេលដែលទ្រង់បានយាងចេញពីផ្នូរ ទ្រង់បានបង្ហាញថា ទ្រង់បានឈ្នះសេចក្តីស្លាប់ហើយ។ គឺនៅពេលនោះហើយ ដែលទ្រង់បានផ្លាស់ប្តូរការគិតរបស់មនុស្ស អំពីសេចក្តីស្លាប់។ ហើយការនេះក៏បានផ្លាស់ប្តូរជីវិតរបស់អ្នកដើរតាមទ្រង់ផងដែរ។

ពេលដែលគេចាប់ខ្លួនព្រះយេស៊ូវ ហើយកាត់ទោសប្រហារជីវិតទ្រង់ មិត្តសំឡាញ់ និងពួកសិស្សទ្រង់បានរត់គេចខ្លួន ដោយការភ័យខ្លាច។ ប៉ុន្តែពេលដែលព្រះយេស៊ូវយាងចេញពីផ្នូរ ពួកសិស្សរបស់ទ្រង់ដែលមានការភ័យខ្លាច ក៏បានប្រែជាមានចិត្តក្លាហានឡើង។ ពួកសិស្សទ្រង់ក៏បានដឹង និងជឿច្បាស់ថា ទ្រង់ពិតជាមានព្រះជន្មរស់ឡើងវិញមែន បានជាពួកគេហ៊ានលះបង់ជីវិត ដើម្បីសេចក្តីជំនឿរបស់ខ្លួន។

ត្រង់ចំណុចនេះ បើសិនជារឿងដែលព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ បីថ្ងៃក្រោយមក គឺរឿងប្រឌិតមែន តើហេតុអ្វីបានជាសិស្សទ្រង់មានការជឿជាក់ច្បាស់ថា ទ្រង់ពិតជាបានមានព្រះជន្មរស់ឡើងវិញមែន? ហើយថែមទាំងហ៊ានលះបង់ជីវិតដើម្បីការពារសេចក្តីពិតនេះថែមទៀត? ជាក់ស្តែង ពួកសិស្សរបស់ទ្រង់ជាច្រើននាក់ ត្រូវបានគេសម្លាប់យាងព្រៃផ្សៃ ដោយសារជំនឿរបស់ពួកគេ។ មនុស្សជាច្រើនទៀតបានជឿពួកគេ ហើយក៏បានស្ម័គ្រចិត្តចូលរួម នៅក្នុងការរងទុក្ខ ដើម្បីប្រកាស់ព្រះបន្ទូលរបស់ព្រះយេស៊ូវ អំពីជីវិតថ្មី។

---

*"ពេលដែលទ្រង់បានយាងចេញពីផ្នូរ ទ្រង់បានបង្ហាញថា ទ្រង់បានឈ្នះសេចក្តីស្លាប់ហើយ។*

---

បើសិនជាព្រះជាម្ចាស់បានប្រោសព្រះយេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញមែន យើងចាំបាច់ត្រូវផ្តោតចិត្តមកលើព្រះបន្ទូល ដែលបានចែងអំពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់។



## ព្រឹត្តិការណ៍ដ៏ជាក់លាក់មួយ

*បងប្អូនអើយ ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងពីដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ជាដំណឹងដែលអ្នករាល់គ្នាបានទទួល ក៏ឈរជាប់ក្នុងនោះផង។ អ្នករាល់គ្នាកំពុងតែបានសង្គ្រោះ ដោយសារដំណឹងល្អនោះផង គឺបើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែង ប្រាប់មក លើកតែអ្នករាល់គ្នាបានជឿ ដោយឥតបើគិត។*

*ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នា តាមសេចក្ដីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ។ ហើយថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ ហើយថា ទ្រង់បានលេចមកឲ្យកេផាសឃើញ រួចដល់ពួក១២នាក់ដែរ។ ក្រោយទៀត ទ្រង់លេចមកឲ្យពួកបងប្អូនជាង៥០០នាក់ឃើញតែម្ដង ជាពួកដែលមានគ្នាច្រើនរស់នៅ ដរាបដល់សព្វថ្ងៃនេះ តែមានខ្លះបានដេកលក់ទៅហើយ។ ក្រោយទៀត ទ្រង់លេចមកឲ្យយ៉ាកុបឃើញ ក៏ឲ្យពួកសាវ័កទាំងអស់គ្នាឃើញដែរ។ រួចទ្រង់បានលេចមកឲ្យខ្ញុំឃើញ ជាខាងក្រោយគេបង្អស់ ដូចជាលេចមកដល់កូនកើតមុនកំណត់ដែរ។* ១កូរិនថូស ១៥:១-៨

**នៅក្នុងសំបុត្រដែលសាវ័កប៉ុល**បានសរសេរផ្ញើពួកជំនុំនៅក្រុងកូរិនថូស គាត់បានពន្យល់យ៉ាងច្បាស់ថា ព្រះយេស៊ូវបានយាងចេញពីផ្នូរ ដោយព្រះកាយដែលមានព្រះជន្មរស់ឡើងវិញ។ នេះជារឿងពិតមែន បានជាគាត់ថែមទាំងបានរំឭកអ្នកអានសំបុត្ររបស់គាត់ អំពីព្រះរាជសារដែលពួកគេបានឮ កាលដែលពួកគេបានទទួលជឿព្រះយេស៊ូវជាលើកដំបូង គឺព្រះរាជសារដែលបានប្រកាស់ថា ព្រះយេស៊ូវគ្រីស្ទបានសុគត ដើម្បីបង់ថ្លៃ

លោះយើងឲ្យរួចពីអំពីបាប ដែលជាការបដិសេធន៍ និងការព្រងើយកន្តើយចំពោះទ្រង់។ គេបានបញ្ចុះព្រះសពទ្រង់ នៅក្នុងផ្នូរ ហើយទ្រង់ក៏បានមានព្រះជន្មរស់ឡើងវិញ គឺដូចដែលព្រះជាម្ចាស់បានសន្យា នៅគ្រាសញ្ញាចាស់។

ទោះជាយ៉ាងណាក៏ដោយ ពួកជំនុំនៅក្រុងកូរិនថូស មិនចេះតែជឿអ្វីដែលគេបានសរសេរ ដោយគ្មានភស្តុតាងនោះទេ។ បើគ្រាន់តែដកស្រង់ខគម្ពីរឲ្យពួកគេមើល ក៏មិនគ្រប់គ្រាន់សម្រាប់ពួកគេដែរ។ ហេតុនេះហើយសាវ័កប៉ុលក៏បានរំឭកពួកគេ អំពីការដែលព្រះយេស៊ូវបានបង្ហាញព្រះអង្គទ្រង់ឲ្យគេបានឃើញជាច្រើនដង បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ។ ហើយទ្រង់ក៏បានជួបស្មរបន្ទាល់សំខាន់ៗ ដែលមានដូចជា សាវ័កពេត្រុស យ៉ាកុប និងប៉ុល បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូវក៏បានជួបសិស្សទ្រង់ជាច្រើនទៀត ដែលរាប់បញ្ចូលទាំងមនុស្សមួយក្រុមដែលមានគ្នាជាង៥០០នាក់។ ដូចនេះ មានស្មរបន្ទាល់ជាច្រើន ដែលបានឃើញទ្រង់។ សូមយើងស្រមៃថា នៅក្នុងការកាត់ក្តីមួយ បើសិនជាមនុស្សជាង៥០០នាក់នោះ ធ្វើជាសាក្សីដែលអាចបញ្ជាក់ថា ពួកគេពិតជាបានឃើញព្រះយេស៊ូវមានព្រះជន្មរស់មែន នោះមានន័យថា មានភស្តុតាងដ៏ច្រើនលើសលប់ ដែលបានបញ្ជាក់ថា ទ្រង់ពិតជាបានមានព្រះជន្មរស់ឡើងវិញ។

---

*"គេបានបញ្ចុះព្រះសពទ្រង់ នៅក្នុងផ្នូរ ហើយទ្រង់ក៏បានមានព្រះជន្មរស់ឡើងវិញ គឺដូចដែលព្រះជាម្ចាស់បានសន្យា នៅគ្រាសញ្ញាចាស់"។*

---

ប៉ុន្តែ ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ បានកើតឡើងជាងពីរពាន់ឆ្នាំហើយ។ យើងមិនអាចទៅសាកសួរសាក្សីទាំងនោះទេ។ ដូចនេះ តើធ្វើដូចម្តេច ឲ្យយើងអាចដឹងច្បាស់ថា ទ្រង់ពិតជាមានព្រះជន្មរស់ឡើងវិញមែន?

យើងអាចគិតថា អ្វីដែលពួកគេបានសរសេរពិតជាបានកើតឡើងមែន

ឬគិតថា ពួកគេគឺជាមនុស្សបោកប្រាស់ ឬឆ្កួត។

ប៉ុន្តែ អ្នកអាចបើកមើលកណ្ឌគម្ពីរដំណឹងល្អយ៉ូហាន ហើយសូមឲ្យនរណាម្នាក់ក្នុងព្រះវិហាររបស់អ្នក ជួយពន្យល់ រួចធ្វើការសម្រេចចិត្តដោយខ្លួនឯង។ លោកយ៉ូហានគឺជាមិត្តសំឡាញ់របស់ព្រះយេស៊ូវ ហើយគាត់បានឃើញព្រះយេស៊ូវសុគតដោយផ្ទាល់។ ប៉ុន្តែ សូមចាំថា លោកយ៉ូហានមិនសក្តិសមនឹងឲ្យយើងហៅគាត់ថា មនុស្សកុហក់ទេ។ តាមធម្មតា មនុស្សកុហក់ទួញយំ ឬមានការស្ដាយក្រោយ ពេលដែលខ្លួនចាប់ផ្តើមរងទុក្ខ ដោយសារការកុហក់របស់ខ្លួន។

តែលោកយ៉ូហាន និងសិស្សដទៃទៀត មិនបានស្រែកយំ ពេលគេដាក់ទោសមកលើខ្លួនឡើយ។ ពួកគេភាគច្រើនបានស្លាប់ ដោយសារការកាត់ទោសប្រហារជីវិត មិនមែនដោយសារពួកគេជាឧក្រិដ្ឋជននោះទេ តែដោយសារពួកគេបានប្រកាស់ប្រាប់គេថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ ហើយបើមិនទទួលជឿព្រះអង្គទេ យើងមិនអាចទទួលសេចក្តីសង្គ្រោះឲ្យរួចពីបាបបានទេ។ បើនេះការកុហក់ តើពួកគេបានចំណេញអ្វីមកវិញ? តាមពិត ការដើរប្រកាស់ប្រាប់គេយ៉ាងដូចនេះ នាំឲ្យពួកគេប្រឈមមុខនឹងការបាត់បង់អ្វីៗគ្រប់យ៉ាង តែពួកគេនៅតែបន្តដើរប្រកាស់។ ប៉ុន្តែ ក្នុងចំណោមពួកគេ គ្មាននរណាម្នាក់ដែលនិយាយថា "យើងបាននិយាយកុហក់ហើយ។ អ្វីៗដែលយើងបានប្រកាស់ប្រាប់គេ គឺសុទ្ធតែជារឿងប្រឌិត"។ ប៉ុន្តែ ហេតុផលដែលយើងអាចយល់បាននោះគឺ ពួកគេបានជឿជាក់ថា ព្រះយេស៊ូវពិតជាមានព្រះជន្មរស់ឡើងវិញមែន គឺមានជំនឿខ្លាំងល្មមនឹងស្ម័គ្រចិត្តស្លាប់ ដោយសារជំនឿនោះ ដោយមិនបានបង្ហាញការសង្ស័យទាល់តែសោះថា អ្វីដែលពួកគេបានប្រកាស់ប្រាប់នោះ មិនមែនជាការពិត។

**ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ** ដែលសាក្សីជាច្រើនដែលបានឃើញផ្ទាល់ភ្នែក និងបានស្ម័គ្រចិត្តស្លាប់ នៅក្នុងការប្រកាស់ថា ទ្រង់ពិតជាមានព្រះជន្មរស់ឡើងវិញមែន។



## ជំនឿដ៏សំខាន់

*បើសិនជាបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ នោះធ្វើដូចម្ដេចឲ្យពួកអ្នករាល់គ្នាខ្លះ និយាយបាន ថាពួកស្លាប់មិនរស់ឡើងវិញទេ។ បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្ដីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ។ ឈ្មោះថាយើងខ្ញុំជាស្មរបន្ទាល់ក្លែងក្លាយពីព្រះវិញ ដ្បិតយើងខ្ញុំបានធ្វើបន្ទាល់ពីព្រះថា ទ្រង់បានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញហើយ តែបើពួកស្លាប់មិនរស់ឡើងវិញមែន នោះប្រាកដជាទ្រង់មិនបានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញពិត។ ដ្បិតបើសិនជាពួកស្លាប់មិនរស់ឡើងទេ នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្ដីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ។*

១កូរិនថូស ១៥:១២-១៧

**អ្នកខ្លះនិយាយថា** ការបង្រៀនអំពីការរស់ពីស្លាប់ឡើងវិញ គឺជាទ្រឹស្ដីចាស់កំរិល។ ប៉ុន្តែ សាវ័កប៉ុលមិនបានឲ្យយើងគិតយ៉ាងដូចនេះទេ។ គាត់បានប្រឆាំងនឹងទស្សនៈនេះដោយចំៗតែម្ដង ហើយក៏បានប្រកាស់យ៉ាងច្បាស់ថា ការបដិសេធន៍ការរស់ឡើងវិញនៅពេលអនាគត គឺជាការបដិសេធន៍សេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់។ ហើយបើយើងមិនបានទទួលសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់ទេ យើងក៏គ្មានមូលដ្ឋានពិតប្រាកដនៃសេចក្ដីសង្ឃឹម បានសេចក្ដីថា យើងកំពុងតែរស់នៅតាមទស្សនវិជ្ជា ដោយប្រាប់ខ្លួនឯងថា "ចូរយើងស៊ីផឹកទៅចុះ ដ្បិតស្អែកយើងត្រូវស្លាប់

ហើយ"(ខ.៣២)។

និយាយរួម ការជឿលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ គឺជាចំណុចស្នូលនៃជំនឿលើព្រះគ្រីស្ទ។ សាវ័កប៉ុលមានប្រសាសន៍ថា ព្រះយេស៊ូវគ្រីស្ទបានសុគត ដើម្បីលោះយើងឲ្យរួចពីបាប ក្នុងកាលដែលយើងនៅបដិសេធទ្រង់នៅឡើយ បានជាយើងគួរតែទុកចិត្តទ្រង់ ហើយងាកបែរមករកទ្រង់វិញ។ ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយបានបង្ហាញព្រះអង្គទ្រង់ ឲ្យមនុស្សជាច្រើនបានឃើញ។ បើយើងបដិសេធថា ព្រះយេស៊ូវមិនបានសុគត ដើម្បីបង់ថ្លៃលោះយើងឲ្យរួចពីបាប ដែលយើងបានធ្វើប្រឆាំងនឹងទ្រង់ គឺមានន័យថា យើងមិនបានទទួលការអត់ទោសបាបទេ។ បើយើងបដិសេធថា ទ្រង់មិនបានមានព្រះជន្មរស់ឡើងវិញ យើងក៏គ្មានក្តីសង្ឃឹមសម្រាប់ពេលអនាគតដែរ។

បើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទជាការពិតមែន នោះយើងក៏នឹងបានរស់ឡើងវិញនៅគ្រាចុងក្រោយផងដែរ។ បើយើងថ្វាយជីវិតយើងដាច់ដល់ព្រះគ្រីស្ទ ដោយជំនឿលើទ្រង់ យើងនឹងបានទទួលការប្រោសឲ្យរស់ពីស្លាប់ឡើងវិញ ដូចទ្រង់ដែរ។ ហើយយើងនឹងបានល្អឥតខ្ចោះ នៅចំពោះព្រះជាម្ចាស់។ ជាងនេះទៅទៀត ឲ្យតែយើងបានធ្វើជាកម្មសិទ្ធិរបស់ទ្រង់ហើយ យើងនឹងមិនដាច់ចេញពីទ្រង់ឡើយ។ ឲ្យតែយើងបានទទួលជឿព្រះគ្រីស្ទហើយ គឺមានន័យថា យើងបានចាប់ផ្តើមជីវិតថ្មីក្នុងទ្រង់ និយាយរួម យើងក្លាយជាកម្មសិទ្ធិរបស់ទ្រង់តែម្តង។ ជីវិតដែលយើងនឹងទៅរស់នៅក្នុងនគរស្ថានសួគ៌ នឹងមានសុវត្ថិភាព និងស្ថិតស្ថេរ ពោលគឺគ្មានអ្វីអាចពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានឡើយ។

---

*"បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ"។*

**១កូរិនថូស ១៥:១៣**

---



# ក្តីសង្ឃឹមដែលធ្វើឲ្យជីវិតផ្លាស់ប្រែ

ការបង្រៀនរបស់សាវ័កប៉ុលអំពីការមានព្រះជន្មរស់ឡើងវិញ បានឈានដល់ចំណុចដែលសំខាន់បំផុត។ ក្នុងបទគម្ពីរ ១កូរិនថូស ១៥:៥០-៥៣ គាត់បាននិយាយដោយសង្ខេបថា *បងប្អូនអើយ សេចក្តីដែលខ្ញុំចង់និយាយនេះ គឺថា សាច់ឈាមពុំអាចនឹងគ្រងនគរព្រះជាមរដកបានឡើយ ហើយសេចក្តីពុករលួយក៏ពុំអាចនឹងគ្រងសេចក្តី ដែលមិនចេះពុករលួយបានដែរ។ នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ។ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ។ ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយសេចក្តីមិនចេះស្លាប់វិញដែរ។*

*អស់អ្នកដែលទទួលជឿព្រះគ្រីស្ទ នឹងបានទទួលជីវិតអស់កល្បជានិច្ច និងរូបកាយថ្មី!*

យើងមិនអាចចូលនគរស្ថានសួគ៌ ដោយរូបកាយដែលយើងមានក្នុងពេលបច្ចុប្បន្នឡើយ។ យើងត្រូវការរូបកាយថ្មីមួយ។ ព្រះជាម្ចាស់បានបើកបង្ហាញដល់សាវ័កប៉ុល នូវសេចក្តីពិតដ៏អស្ចារ្យដែលថា នៅថ្ងៃមួយ ព្រះគ្រីស្ទនឹងយាងត្រឡប់មករកអ្នកដែលបានទទួលជឿទ្រង់។ ពេលដែលគ្រីស្ទបរិស័ទស្លាប់ទៅ ពួកគេនឹងបានផ្លាស់ប្រែរូបកាយដែលបានកើតនៅផែនដី ហើយទទួលរូបកាយដ៏ល្អឥតខ្ចោះសម្រាប់រស់នៅក្នុងនគរស្ថានសួគ៌។

---------------

*«សេចក្ដីជ័យជំនះ បានលេបសេចក្ដីស្លាប់បាត់ហើយ»។*

**១កូរិនថូស ១៥:៥៤**

---------------

អស់អ្នកដែលទទួលជឿព្រះគ្រីស្ទ នឹងបានទទួលជីវិតអស់កល្បជានិច្ច និងរូបកាយថ្មី! ត្រង់ចំណុចនេះ សាវ័កប៉ុលក៏បានបន្លឺសម្លេងសរសើរដំកើងដោយអំណរថា "កាលណារូបកាយពុករលួយនេះ បានប្រដាប់ដោយសេចក្ដីមិនពុករលួយ ហើយរូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់វិញ នោះទើបនឹងបានសំរេចតាមពាក្យ ដែលចែងទុកមកថា «សេចក្ដីជ័យជំនះបានលេបសេចក្ដីស្លាប់បាត់ហើយ»។ «ឱសេចក្ដីស្លាប់អើយ ទ្រនិចឯងនៅឯណា សេចក្ដីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា»។ រីឯទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រឹត្យវិន័យ។ តែអរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឲ្យយើងរាល់គ្នាមានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង"(ខ.៥៤-៥៧)។ ទ្រង់បានឈ្នះអំពើបាប និងសេចក្ដីស្លាប់ ដែលជាខ្មាំងសត្រូវរបស់យើងហើយ។ តាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ទ្រង់បានឈ្នះសេចក្ដីស្លាប់ទាំងស្រុង បានជាជ័យជម្នះនោះនឹងលេបសេចក្ដីស្លាប់។

សាវ័កប៉ុលថែមទាំងបានចម្អកឲ្យសេចក្ដីស្លាប់ថា "ឱសេចក្ដីស្លាប់អើយ ទ្រនិចឯងនៅឯណា សេចក្ដីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា?" ទ្រនិចនៃសេចក្ដីស្លាប់ គឺជាអំពើបាប ព្រោះសេចក្ដីស្លាប់ គឺជាទោសដែលមនុស្សត្រូវទទួល សម្រាប់ការធ្វើបាបទាស់នឹងព្រះ។ ប៉ុន្តែ ព្រះយេស៊ូបានរស់នៅក្នុងជីវិតដ៏ល្អឥតខ្ចោះជំនួសយើង ហើយតាមរយៈការសុគតរបស់ទ្រង់ ទ្រង់បានបង់ថ្លៃលោះយើងឲ្យរួចពីបាប ដោយវាយបំបាក់អំណាច ដែលវាមានមកលើយើង។ ទ្រង់បានឈ្នះអំពើបាប និងសេចក្ដីស្លាប់។ យើងមិនចាំបាច់ត្រូវភ័យខ្លាចឡើយ។

បន្ទាប់ពីសាវ័កប៉ុលបានសរសើរដំកើងព្រះ សម្រាប់ជ័យជម្នះនេះ ហើយ គាត់ក៏បានជំរុញយើងរាល់គ្នាថា "បានជាបងប្អូនស្ងួនភ្ងាអើយ ចូរកាន់យ៉ាងខ្ជាប់ខ្ជួន ដោយឥតរង្គើ ទាំងធ្វើការព្រះអម្ចាស់ ឲ្យបរិបូរជាដរាបចុះ ដោយដឹងថា ការដែលអ្នករាល់គ្នាខំប្រឹងធ្វើក្នុងព្រះអម្ចាស់ នោះមិនមែនឥតប្រយោជន៍ទេ"(ខ.៥៨)។

យើងនឹងបានទទួលរង្វាន់នៃនគរស្ថានសួគ៌ ដោយសារព្រះរាជកិច្ចរបស់ព្រះគ្រីស្ទ។ ដោយសារព្រះបន្ទូលសន្យាដ៏អស្ចារ្យនេះ យើងអាចរស់នៅថ្វាយព្រះ ទោះជាមានឧបសគ្គអ្វីក៏ដោយ។ ហើយរង្វាន់នោះ នឹងល្អលើសបញ្ហា ឬការឈឺចាប់ ដែលយើងត្រូវឆ្លងកាត់ក្នុងជីវិតនេះ។

*បើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទជាការពិតមែន នោះយើងក៏នឹងបានរស់ឡើងវិញនៅគ្រាចុងក្រោយផងដែរ។*

តើយើងនឹងធ្វើការសម្រេចចិត្តយ៉ាងណា? យើងអាចបដិសេធព្រះយេស៊ូវ ដោយបន្តនៅដាច់ចេញពីព្រះ ហើយរស់នៅក្នុងការភ័យខ្លាចចំពោះដង្ហើមចុងក្រោយរបស់យើង។ ពុំនោះទេ យើងអាចទទួលជឿព្រះយេស៊ូវ ដោយជឿថា ទ្រង់បានសុគតជំនួសយើង ហើយជឿច្បាស់ថា ទ្រង់នឹងនាំយើងវិលត្រឡប់ទៅរកទ្រង់វិញ ដើម្បីឲ្យយើងបានរស់នៅជាមួយទ្រង់ជារៀងរហូត។ ដរាបណាយើងនៅមានដង្ហើម យើងនៅមិនទាន់យឺតពេល នៅក្នុងការងាកមករកព្រះយេស៊ូវ។ យើងត្រូវដឹងថា ព្រះអម្ចាស់ដែលបានមានព្រះជន្មរស់ឡើងវិញ បានប្រទានឲ្យយើងនូវក្តីសង្ឃឹមថា យើងនឹងបានរស់ឡើងវិញនៅពេលអនាគត។ យើងអាចដឹងថា ជីវិតថ្មីកំពុងតែរង់ចាំយើង បន្ទាប់ពីយើងស្លាប់ទៅ។ បើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទគឺជាការពិត នោះយើងក៏នឹងរស់ឡើងវិញនៅគ្រាចុងក្រោយផងដែរ។